ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ............ សហវ ...........

រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្តីពីការងារស្ថាបនាផ្លូវក្រាលក្រួសក្រហម ឬដីល្បាយកំទេចថ្មភ្នំ ចំនួន ០១ខ្សែ ប្រវែង ៤១ ០០០ម ទទឹង ០៧ម កម្រាស់ ០,២ម ទទឹងដីស ០៨ម ស្ថិតនៅខេត្តស្ទឹងត្រែង។

**យោង:** - លិខិតលេខ ៤៥៥៤ សហវ.អថ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៨៩៥/១៧ ក.អ.ជ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការនៃក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវក្រាលក្រួសក្រហម ឬដីល្បាយកំទេចថ្មភ្នំ ចំនួន ០១ខ្សែ ប្រវែង ៤១ ០០០ម ទទឹង ០៧ម កម្រាស់ ០,២ម ទទឹងដីស ០៨ម ស្ថិតនៅតាមបណ្តោយផ្លូវខ្សែក្រវ៉ាត់ព្រំដែនកម្ពុជា-ឡាវ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ក្នុងតម្លៃសរុបចំនួន ១២ ២៥៩ ០០០ ០០០រៀល (ដប់ពីរប៊ីលាន ពីររយហាសិបប្រាំបួនលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ នៃក្រសួងការពារជាតិ
- នាយកដ្ឋានផ្លូវលំជនបទ
- សាលាខេត្តស្ទឹងត្រែង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្ទឹងត្រែង
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798